# ចិត្តវិទ្យា

១- ចិត្តវិទ្យា ជាអ្វី ?

ចំៈ ចិត្តវិទ្យា គឺ ជាវិទ្យាសាស្ត្រដែលសិក្សាពីបាតុភូតចិត្ត ។

២- ហេតុអ្វីបានជាគេនិយាយថា ចិត្តវិទ្យាជាវិទ្យាសាស្ត្រ ?

ចំៈ ព្រោះ ចិត្តវិទ្យាមានកម្មវត្ថុសិក្សាច្បាស់លាស់មានវិធីសិក្សាច្បាស់លាស់ និង នាំមកនូវផលប្រយោជន៍ដល់សង្គមមនុស្ស ។

៣- ដូចម្តេចដែលហៅថា បាតុភូតចិត្ត ?

ចំៈ គឺជាបាតុភូតទាំងឡាយដែលប្រព្រឹត្តទៅនៅក្នុងខួរក្បាលរបស់មនុស្ស និង សំដែងចេញមកក្រៅតាមរយៈ អំពើ និង អាកប្បកិរិយា (កាយវិការ ទឹកមុខ ពាក្យសំដី ……) ។

៤- ដូចម្តេចដែលហៅថាធម្មជាតិនៃបាតុភូតចិត្ត? មានអ្វីខ្លះ?

ចំៈ គឺ ចិត្តជារូបភាពអត្តនោម័ត នៃ តថភាពបរានុម័តក្នុងខួរក្បាលរបស់មនុស្សម្នាក់ៗ ។ វាមានចរិតសង្គមប្រវត្តិ ។

មានៈ
– តថភាពបរានុម័ត
– ចរិតអត្តនោម័តរបស់ចិត្ត
– ចិត្តជាមុខងាររបស់ខួរក្បាល
– ចិត្តជាបទពិសោធន៍ដែលមានចរិត សង្គមប្រវត្តិ ហើយដែលមនុស្សបានប្រែក្លាយជាសម្បត្តិផ្ទាល់ខ្លួន ។

៥- ដូចម្តេចដែលហៅថាតថភាពបរានុម័ត ឬ ពិភពបរានុម័ត?

ចំៈ គឺជាអ្វីៗទាំងអស់ " រូបធាតុក្តី គំនិតក្តី " ដែលនៅក្រៅខ្លួន ហើយមិនចំណុះញាណ និង ឆន្ទៈយើងទេ ។ វាត្រូវបានឆ្លុះ បញ្ចាំងចូលក្នុងខួរក្បាលរបស់មនុស្ស ហើយបង្កើតបានជារូបភាពចិត្ត ។ រូបភាពចិត្តផ្សារភ្ជាប់តថភាពបរានុម័តយ៉ាងជិតស្និតទៅនឹងខួរក្បាល ។ ហើយដោយសារតែមនុស្សមានទំនាក់ទំនងជាមួយមជ្ឈដ្ឋានជុំវិញ ដូចនេះរូបភាពចិត្តកកើតមានឡើងគ្រប់ពេលវេលា ។

## ៦- ចរិតអត្តនោម័តរបស់ចិត្តជាអ្វី ?

ចំៈ រូបភាពចិត្តនៃ វត្ថុមួយ ឬ បាតុភូតមួយ មានភាពខុសប្លែកគ្នាពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតពីព្រោះ ការឆ្លុះបញ្ចាំងតាមខួរក្បាលនេះ វាផ្លាស់ប្តូរទៅតាមបទពិសោធន៍ និង វិសេសភាពរបស់បុគ្គលម្នាក់ៗ ។

ឧៈ គំហើយខុសគ្នានៃផ្លែស្វាយមួយ ដោយមនុស្សធម្មតាមនុស្សឈឺក្រពះ និង ស្ត្រីមានពោះ ។

## ៧- តើចិត្តមានមុខងារប៉ុន្មានយ៉ាង? អ្វីខ្លះ ?

ចំៈ មានមុខងារ ៣ យ៉ាង គឺៈ

– តំរង់ទិស ណែនាំ ដឹកនាំអំពើរបស់មនុស្ស ។
ឧៈ អ្នកប្រមាញ់សំដៅទៅកន្លែងដែលសត្វយំ ។

– រុញច្រាន ធ្វើអោយកាន់តែខ្លាំងនូវអំពើ ទាំងឡាយ ។
ឧៈ ទឹកចិត្តឪពុកម្តាយស្រឡាញ់កូន ធ្វើអោយកូនហ៊ានតស៊ូ ខិតខំ ប្រឹងប្រែងក្នុងការការរៀនសូត្រ ការងារ ។

– តំរែតំរង់ កែតំរូវអំពើៈ នៅក្នុងសកម្មភាព គេអាចភាន់ច្រលំ ។
គោលបំណងដែលបានកំនត់ជួយអោយមានភាពត្រឹមត្រូវពិតប្រាកដ និង មានប្រយោជន៍ ។

## ៨- បាតុភូតចិត្តមានប៉ុន្មានប្រភេទ ? អ្វីខ្លះ ?

ចំ: មានបីប្រភេទ គឺ:

– លំនាំចិត្ត: ជាបាតុភូតទាំងឡាយណា ដែលប្រព្រឹតទៅក្នុងរយៈ ពេលមួយខ្លី វាអាចចាប់ផ្តើម ការប្រព្រឹត្តទៅ និង ការបញ្ចប់ ។

– សភាពចិត្ត: ជាបាតុភូតចិត្ត ដែលប្រព្រឹត្តទៅអស់រយៈពេលយូរបន្តិច ។ ជាធម្មតាសភាពចិត្តដើរតាមលំនាំចិត្តដទៃទៀត ដោយ យកលំនាំចិត្តទាំងនោះធ្វើជាបង្អែក ។

– លក្ខណៈចិត្ត: ជាបាតុភូតចិត្តទាំងឡាយដែល ប្រព្រឹត្តទៅអស់រយៈពេលយ៉ាងវែងជូនកាលរហូតអស់មួយជីវិត ហើយមានសភាពនឹងនរ ចំពោះបុគ្គលមួយជាក់លាក់ ។

## ៩- តើវិធីសិក្សាចិត្តវិទ្យាមានប៉ុន្មានយ៉ាង ? អ្វីខ្លះ ?

ចំ: មាន ៦ យ៉ាង គឺ:

–វិធីសង្កេត: ជាវិធីគេប្រើច្រើនជាងគេក្នុងចិត្តវិទ្យា ។ វិធីនេះ សិក្សាអំពីសកម្មភាព (កាយវិការ ទឹកមុខ ពាក្យសម្តី .....) របស់មនុស្សម្នាក់ៗ ដើម្បីស្គាល់ពីគុណសម្បត្តិ និង គុណវិបត្តិ របស់ មនុស្សនោះ ។

ឧ: សង្កេតទៅលើចណ្ឌលចិត្ត និង តំរូវការរបស់អតិថិជន ។

–វិធីវិភាគផលិតផលសកម្មភាព: នៅពេលដែលមនុស្សបង្កើតផលិតផលគឺ ពួកគេបាន បន្សល់ទុកនូវស្នាកស្នាមបុគ្គលិកលក្ខណៈរបស់ពួកគេក្នុងលទ្ធផលនេះ ។ ដូចនេះ ឆ្លងកាត់តាម ផលិតផលយើងនឹងដឹងពីអត្តចរិត ឬ ឫកពាររបស់មនុស្សបាន ។

ឧ: តាមរយៈប្រាសាទ អង្គរ វត្ត ដែលបានបន្សល់ទុក នាំអោយយើងដឹងពីស្នាដៃរបស់បុព្វបុរសខ្មែរសម័យនោះថាជាមនុស្សឧស្សាហ៍ និងជាមនុស្សដែលមានការបំរុងប្រយ័ត្នខ្ពស់ ។

– វិធីសន្ទនា: ជាលំនាំសួរនិងឆ្លើយដោយផ្ទាល់ រវាងអ្នកស្រាវជ្រាវ ។ ហើយ ដោយសារសំនួរទាំងឡាយដែលបានគ្រោងទុកមុនយើងអាចស្គាល់បានពីចិត្តកំនិត អាថិកំបាំងរបស់មនុស្សតាម ការវិភាគលើប្រតិកម្មសំដីរបស់មនុស្សដែលយើង សន្ទនាជាមួយ ។

– វិធីអង្កេត: យើងរៀបរាប់កំរងសំនួរដាក់ក្នុងក្រដាសមួយ ហើយចែកអោយកម្មវត្ថុ ស្រាវជ្រាវ និង អនុញ្ញាតអោយគេបំពេញរាល់សំនួរដែលមាននោះ បន្ទាប់មកទើប យើងប្រមូលចំលើយ

ហើយធ្វើការបូកសរុប ។

– វិធីតេស្ត: តេស្តជាប្រភេទលំហាត់ដែលគេដាក់អោយកម្មវត្ថុធ្វើ

– វិធីពិសោធន៍: វិធីនេះមានបំណងបង្កបាតុភូតចិត្តដែលត្រូវសិក្សា ដើម្បីអាចសង្កេត ពី បំរែបំរួលធាតុផ្សេងៗរបស់បាតុភូតនោះ ។ វិធីនេះអាចប្រព្រឹត្តទៅក្រោមរូបភាពពីរ គឺ ពិសោធន៍ធម្មតា និង ពិសោធន៍នៅក្នុងមន្ទីរពិសោធន៍ ។

១០- តើសកម្មភាពពុទ្ធិមានប៉ុន្មានយ៉ាង ? អ្វីខ្លះ ?

ចំ: មានពីរ គឺ:

– ពុទ្ធិឥន្ទ្រីយ៍: ជាលំនាំពុទ្ធិដែលឆ្លុះបញ្ជាំងតថភាពបរានុម័ត ដោយប្រើឥន្ទ្រីយ៍ ។

ពុទ្ធិឥន្ទ្រីយ៍មាន ឥន្ទ្រីយារម្មណ៍ និង ប្រត្យក្សារម្មណ៍ ។

– ពុទ្ធិវាចារ: ជាលំនាំពុទ្ធិដែលឆ្លុះបញ្ជាំងដោយប្រយោពីលក្ខណ: ខាងក្នុងនៃវត្ថុ ឬ បាតុភូត ដែលកន្លងហួសមកហើយ ឬ ដែលស្ថិតនៅចំពោះមុខ ឬ នៅអនាគត ហើយ បង្កើតបានជា

សញ្ញាណអរូបី និង ទូទៅ ។

១១- ដូចម្តេចដែលហៅថាឥន្ទ្រីយារម្មណ៍ ?

ចំ: គឺជាលំនាំចិត្តសាមញ្ញបំផុតដែលឆ្លុះបញ្ចាំងលក្ខណៈដាច់តែឯងនៃវត្ថុ ឬ បាតុភូតទាំងឡាយដែលប្រព្រឹត្តផ្ទាល់មកលើសរីរាង្គ ឥន្ទ្រីយ៍។ ឥន្ទ្រីយារម្មណ៍ឆ្លុះបញ្ចាំងផងដែរនូវសភាពខាងក្នុងនៃសារពាង្គកាយ ។

ឧ: ហូបនំ ច្រមុះដឹងក្លិន អណ្តាតដឹងរសជាតិ .

១២- ដូចម្តេចដែលហៅថាប្រត្យក្សារម្មណ៍ ?

ចំ: គឺជាលំនាំចិត្តដែលឆ្លុះបញ្ចាំងទាំងស្រុងនូវលក្ខណៈ ឬ បាតុភូត ដែលប្រព្រឹត្តផ្ទាល់មកលើសរីរាង្គឥន្ទ្រីយ៍ ។

១៣- ប្រៀបធៀប ឥន្ទ្រីយារម្មណ៍ និង ប្រត្យក្សារម្មណ៍ ?

ចំ: + លក្ខណៈដូចគ្នា:

– ឆ្លុះបញ្ចាំងពីវត្ថុ ឬ បាតុភូតដែលប្រព្រឹត្តផ្ទាល់មកលើសរីរាង្គឥន្ទ្រីយ៍ ។

+ លក្ខណៈខុសគ្នា

ឥន្ទ្រីយារម្មណ៍ ប្រត្យក្សារម្មណ៍

– ផ្តល់នូវលក្ខណៈទោលនៃវត្ថុ – ផ្តល់នូវលក្ខណៈទាំងស្រុង ឬបាតុភូត នៃវត្ថុទាំងមូល

– លទ្ធផលឥន្ទ្រីយារម្មណ៍ផ្សេងៗ – លទ្ធផលរូបភាព ។

១៤- ដូចម្តេចដែលហៅថាលំនឹក ?

ចំ: គឺជាលំនាំចិត្តដែលថតយក ផ្តិតយក រក្សាទុកស្គាល់ឡើងវិញ និងបង្កើតឡើងវិញនូវរូបភាពនៃវត្ថុ ឬ បាតុភូតដែលគេបានជួប ប្រទះពីមុន និង បទពិសោធន៍ទាំងឡាយ ដែលមនុស្សម្នាក់ៗបានឆ្លងកាត់ក្នុងអតីតកាល ។

## ១៥- ការគិតជាអ្វី ? មានប៉ុន្មាន ? អ្វីខ្លះ ?

ចំ: គឺជាលំនាំចិត្តដែលឆ្លុះបញ្ចាំងនូវលក្ខណៈសំខាន់ៗ ទំនាក់ទំនងខាងក្នុង ដែលមានចរិតជាក្រឹតក្រមនៃវត្ថុ ឬ បាតុភូតដែលពុទ្ធិឥន្ទ្រីយ៍ ពុំអាចឆ្លុះបញ្ចាំងបានពីលក្ខណៈទាំងនោះ ។

– ការគិតមានបីប្រភេទគឺ:

+ ការគិតរូបីដោយដៃ

+ ការគិតរូបីដោយរូបភាព

+ ការគិតអរូបី

## ១៦- ដូចម្តេចដែលហៅថារូបារម្មណ៍ ?

ចំ: គឺជាលំនាំចិត្តដែលឆ្លុះបញ្ចាំងវត្ថុទាំងឡាយដែលពុំទាន់កើតមាននៅឡើយ ក្នុងបទពិសោធរបស់បុគ្គល ។

លំនាំនេះ ប្រព្រឹត្តទៅដោយបង្កើតរូបភាពថ្មីៗ ដែលចាប់ផ្តើមពី រូបតំណាងចាស់ៗទាំងឡាយ ។

*** មូលដ្ឋានរូបធាតុនៃបាតុភូតចិត្តគឺ ខួរក្បាល និង សំបកខួរក្បាល ។

## ១៧- ភាសាជាអ្វី ?

ចំ:គឺជាការប្រមូលផ្តុំនៃប្រព័ន្ធសញ្ញាទាំងឡាយដែលជាគ្រឹះក្នុងការធ្វើទំនាក់ទំនងរវាងមនុស្សក្នុងសង្គម ។ ភាសាជាការសម្តែងសកម្មភាពដោយនិមិត្តរបស់មនុស្សពោលគឺ សម្បទារបស់គេ ក្នុងការសម្តែងចិត្តគំនិត និង ជាហេតុការណ៍នានាតាមសូរសំលេង និង កាយវិការ ។

សរុបមក ភាសាគឺជាឧបករណ៍នៃគំនិតដែលមនុស្សបង្កើតឡើងសំរាប់បញ្ជូលទំនាក់ទំនងក្នុងសង្គម ។

១៨- ចូរអោយនិយមន័យចិត្តរំភើប សញ្ចេតនា ?

ចំ: គឺជាឥរិយាបថចំពោះវត្ថុ ឬបាតុភូតបរានុម័តទាំងឡាយដែលទាក់ទងទៅនឹងការពេញចិត្ត ឬ មិនពេញចិត្តនៃតំរូវការផ្នែកសំភារ: និង ស្មារតី ។

១៩- ឥន្ទ្រីយារម្មណ៍ក្រៅមាន ៥

– ចក្ខុឥន្ទ្រីយារម្មណ៍ ឬ ចក្ខុវិញ្ញាណ

– សោតិន្ទ្រីយារម្មណ៍ ឬ សោតវិញ្ញាណ

– ឃានិន្ទ្រីយារម្មណ៍ ឬ ឃានវិញ្ញាណ

– ជីវ្ហិន្ទ្រីយារម្មណ៍ ឬ ជីវ្ហាវិញ្ញាណ

– កាយិន្ទ្រីយារម្មណ៍ ឬ កាយវិញ្ញាណ

២០- មូលដ្ឋានសរីរ:មាន:

– សរីរាង្គទទួល – សរសៃប្រសាទ ប្រទាញ

– ផ្នែកមួយដែលទាក់ទងនឹង អឌ្ឍគោលខួរ

២១- ច្បាប់នៃឥន្ទ្រីយារម្មណ៍ មានបួន គឺ

– ច្បាប់ព្រំ – ច្បាប់បន្សុំ

– ច្បាប់អំពើប្រតិឃាដរវាងឥន្ទ្រីយារម្មណ៍នានា

– ច្បាប់ផ្ទុយគ្នានៃឥន្ទ្រីយារម្មណ៍ ។

២២- ច្បាប់ផ្សេងៗនៃប្រត្យក្សារម្មណ៍ មានៈ

– ច្បាប់ជំរើស – ច្បាប់អត្ថន័យ

– ច្បាប់ស្ថិរភាព – ច្បាប់មាយាការ